អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

*សេចក្តីណែនាំអនុវត្ត ០៣/២០០៧*

# វិធានការការពារ

**គណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

**ដោយពិចារណាទៅលើ** កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចុះហត្ថលេខានាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ (ដែលបន្ទាប់ពីនេះ ហៅកាត់ខ្លីថា "**កិច្ចព្រមព្រៀង**")។

**ដោយពិចារណាទៅលើ** ច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងវិសោធនកម្មដែលត្រូវបានអនុម័តប្រកាសអោយប្រើប្រាស់នាថ្ងៃទី២៧ ខែតុលា ២០០៤ (ដែលបន្ទាប់ពីនេះ ហៅកាត់ខ្លីថា"**ច្បាប់អ.វ.ត.ក**")។

**ដោយពិចារណាទៅលើ** វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ដែលបានអនុម័តដោយកិច្ចប្រជុំពេញអង្គចៅក្រមនៅថ្ងៃទី ១២ ខែមិថុនា ២០០៧ និងត្រូវបានចុះហត្ថលេខាអោយចូលជាធរមាននាថ្ងៃទី ១៩ ខែមិថុនា ២០០៧។

**អនុលោម**ទៅតាមវិធាន ២០(៣)នៃវិធានផ្ទៃក្នុងនៃអ.វ.ត.ក ដែលចែងអំពីគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង ក្នុងការធ្វើការអនុម័តលើសេចក្តីណែនាំអនុវត្តដែលទាក់ទងទៅនឹងដំណើរការនៃ អ.វ.ត.ក ហើយដែលត្រូវពិនិត្យឡើងវិញដោយកិច្ចប្រជុំពេញអង្គនៅក្នុងកិច្ចប្រជុំពេញអង្គនាពេលបន្តបន្ទាប់ ។

**តាមន័យដូចខាងលើនេះ សម្រេចចេញ** សេចក្តីណែនាំអនុវត្តអំពីវិធានការការពារ (ដែលបន្ទាប់ពីនេះ ហៅកាត់ខ្លីថា"**សេចក្តីណែនាំអនុវត្ត ០៣/២០០៧**")

## មាត្រា ១. **បទប្បញ្ញត្តិទូទៅ**

១.១ ដីកាសំរេចអំពីវិធានការការពារត្រូវធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះតាមគំនិតផ្តួចផ្តើមរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដោយផ្ទាល់ ឬសំណើរបស់ភាគីណាមួយ ឬមេធាវីរបស់ភាគីណាមួយ ដោយអនុលោមទៅតាមវិធាន២៨ និង២៩នៃវិធានផ្ទៃក្នុង ។

១.២ ដីកាសំរេចអំពីវិធានការការពារ អាចត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដើម្បីការពារសន្តិសុខដល់ជនរងគ្រោះ ដែលជាអ្នកប្តឹង ឬ ជាដើមបណ្តឹងរដ្ឋប្បវេណី និង ជាសាក្សី។

១.៣ នៅពេលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះសំរេចចេញដីកាសំរេចអំពីវិធានការការពារ ដើម្បីការពារសន្តិសុខដល់ជនរងគ្រោះ ឬ សាក្សី សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវគោរពគោលការណ៍ជាមូលដ្ឋានដែលអនុវត្តនៅក្នុងដំណើរការនីតិវិធីនៃអ.វ.ត.ក ជាពិសេសដូចជាៈ

ក.អំពីតំរូវការជនរងគ្រោះ និង សាក្សី

ខ.អំពីសិទ្ធិជនសង្ស័យ ឬ ជនដែលត្រូវចោទ ឬ ជនជាប់ចោទ និង

គ.នីតិវិធីនៃការជំនុំជម្រះមួយដែលត្រឹមត្រូវ និងមិនលំអៀង

១.៤ មុននឹងចេញដីកាសំរេចអំពីវិធានការការពារនេះ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវធ្វើការវាយតំលៃអោយបានល្អិតល្អន់អំពីអង្គហេតុដែលពាក់ព័ន្ធ ។ ជាពិសេស ក្នុងការកំណត់ថាតើវិធានការដែលចេញនោះ មានភាពសមស្របដែរឬទេ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះក៏ត្រូវពិចារណាផងដែរ អំពីសមាមាត្រភាពរវាងវិធានការការពារ ដែលបានដាក់ចេញ និង ហានិភ័យដែលអាចកើតមានឡើង ។

១.៥ ក្នុងការកំណត់ភាពសមស្របនៃវិធានការការពារ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវស្វែងរកការយល់ព្រម ពីបុគ្គលដែលត្រូវការពារដោយវិធានការនោះ ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវព្យាយាមជូនដំណឹងទៅបុគ្គលនោះ មេធាវីរបស់ពួកគេ អំពីទស្សនៈ និងផលប៉ះពាល់នៃវិធានការការពារនោះ ។

**មាត្រា ២.នីតិវិធីនៃការអនុវត្តវិធានការការពារ**

២.១ ដោយអនុលោមទៅតាមវិធាន ២៩(៣) ការស្នើសុំវិធានការការពារ ដែលធ្វើដោយភាគី ឬ មេធាវីរបស់ភាគី ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយដាក់ទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ។

២.២ ការស្នើសុំដែលធ្វើចំពោះសាក្សី ឬជនរងគ្រោះពិសេសណាមួយ សំណើនោះត្រូវបញ្ជូនទៅសាក្សី ឬ ជនរងគ្រោះនោះ ឬមេធាវីនៃបុគ្គលនោះ ឬ អង្គភាពគាំពារសាក្សី/អ្នកជំនាញ ឬ អង្គភាពជនរងគ្រោះ ទៅតាមករណីសមស្រប ដោយអនុលោមទៅតាមវិធាន ៤៦ នៃវិធានផ្ទៃក្នុង។

២.៣ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវពិគ្រោះយោបល់ជាមួយអង្គភាពជនរងគ្រោះ ឬ អង្គភាពគាំពារសាក្សី/អ្នកជំនាញ ទៅតាមករណីសមស្របនីមួយៗ ។ ប្រសិនបើយល់ឃើញថាសម

ស្រប សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប អាចពិគ្រោះយោបល់ផង ដែរ ជាមួយបុគ្គលដែលពាក់ព័ន្ធ (ក្នុងករណីចាំបាច់ ការពិគ្រោះយោបល់ធ្វើឡើងដោយមានមេធាវី របស់ពួកគេ) សហព្រះរាជអាជ្ញា ផ្នែកសន្តិសុខ និងជនសង្ស័យ ឬ ជនត្រូវចោទ ឬ ជនជាប់ចោទ និងមេធាវីរបស់ជននោះបាន ។

២.៤ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬ ការស្នើសុំ អាចបើក សវនាការសំងាត់ដើម្បីសំរេចអំពីវិធានការការពារ ។សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច ប្រើប្រាស់មធ្យោបាយពីចំងាយ ដើម្បីអោយភាគីណាមួយ ឬភាគីនានាដែលពាក់ព័ន្ធចូលរួមបាន ។

២.៥ អង្គភាពជនរងគ្រោះ ឬអង្គភាពគាំពារសាក្សី/អ្នកជំនាញ អាចលើកជាសំនួរទៅសហចៅក្រមស៊ើប អង្កេតឬអង្គជំនុំជម្រះ តាមករណីសមស្របទាក់ទងទៅនឹងការសំរេចចេញវិធានការការពារ ឬការ ផ្លាស់ប្តូរ ដោយលើកមូលហេតុជាលាយលក្ខណអក្សរ ។

២.៦ នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះចេញវិធានការការពារ រាល់ឯកសារដែល ពាក់ព័ន្ធនឹងដីកានោះ ត្រូវធ្វើកំណត់ត្រាទុកនៅក្នុងសំណុំឯកសារមួយ ដាច់ដោយឡែកពីសំណុំរឿង និងត្រូវគ្រប់គ្រងដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសម ស្រប ។ ការពិនិត្យមើលសំណុំឯកសារនេះ ត្រូវទទួលការអនុញ្ញាតជាមុនពីសហចៅក្រមស៊ើប អង្កេត ឬ អង្គជំនុំជម្រះ ។

**មាត្រា ៣.វិសាលភាពនៃវិធានការការពារ**

៣.១ បន្ថែមពីលើវិធានការការពារ ដែលមានចែងនៅក្នុងវិធាន ២៩(៤) នៃវិធានផ្ទៃក្នុង សហចៅក្រម ស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាចចេញវិធានការការពារដូចខាងក្រោម:

ក.បង្គាប់អោយធ្វើកំណត់ហេតុជាលាយលក្ខណ៏អក្សរ ឬ កំណត់ហេតុនៃផ្នែកពិសេសណាមួយនៃ នីតិវិធី ដោយរក្សាទុកតាមរបៀប “បិទស្លាកបោះត្រា” ។

ខ. ហាមឃាត់សាធារណៈជនចូលពិនិត្យឯកសារពិសេសណាមួយក្នុងសំណុំរឿង ឬ ទទួលបាននូវ សំណុំឯកសារដែលបង្ហាញពីអត្តសញ្ញាណនៃបុគ្គលដែលត្រូវការពារ ។

គ.ចេញវិធានការដើម្បីការពារជារូបវន្តដល់បុគ្គលដែលត្រូវការពារ ជាពិសេសការផ្តល់ជាកន្លែង ស្នាក់នៅដែលមានសុវត្ថិភាពនៅក្នុង ឬក្រៅប្រទេសកម្ពុជា ដោយអនុលោមទៅតាមកិច្ចព្រមព្រៀង ស្តីអំពីការផ្លាស់ប្តូរលំនៅដ្ឋាន ។

ឃ.បន្ថែមពីលើវិធាន ២៩(៤)(ខ) ដកចេញនូវរាល់កំណត់ហេតុទាំងឡាយពីសំណុំរឿងដែលអោយ គេស្គាល់នូវអត្តសញ្ញាណរបស់បុគ្គលដែលត្រូវការពារ ឬ ព័ត៍មានផ្សេងទៀត ដែលអាចបង្ហាញ អំពីអត្តសញ្ញាណ ឬ ទីកន្លែង ។

៣.២ ដើម្បីអនុវត្តវិធានការការពារ ជាពិសេសបិតក្នុងអំឡុងពេលនៃនីតិវិធីតទល់គ្នារបស់ភាគី និង សវនាការ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចប្រើមធ្យោបាយអេឡិចត្រូនិចដូច ខាងក្រោមៈ

ក. ការបំប្លែងសម្លេង ឬ ទម្រង់រូបកាយរបស់បុគ្គលដែលត្រូវការពារ ។

ខ. ការប្រើប្រព័ន្ធរូបភាព និងសំលេង ជាពិសេសVideoconferencing or closed circuit television ។

គ. ការប្រើតែមធ្យោបាយសម្លេងក្នុងការទំនាក់ទំនង ។

ឃ. មធ្យោបាយអេឡិចត្រូនិចដទៃទៀតទាំងអស់ ដែលអាចការពារបុគ្គលដែលត្រូវការពារនោះ។

៣.៣ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប ត្រូវធានាថា នៅមុនពេលផ្តល់ ធាតុផ្សំនៃភស្តុតាងណាមួយ បុគ្គលដែលត្រូវការពារត្រូវបានផ្តល់ព័ត៌មានថាសក្ខីកម្មរបស់ខ្លួន ឬ អត្តសញ្ញាណរបស់បុគ្គលនោះ អាចនឹងត្រូវបញ្ចេញឱ្យដឹងនៅក្នុងដំណាក់កាលនៃសំណុំរឿងផ្សេង យោងតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា៤ នៃសេចក្តីណែនាំអនុវត្តនេះ ។

## មាត្រា ៤. ការផ្លាស់ប្តូរវិធានការការពារ

៤.១ បន្ទាប់ពីវិធានការការពារត្រូវបានចេញ វិធានការការពារនោះ នឹងត្រូវបន្តយកមកអនុវត្តដូចគ្នាក្នុង កិច្ចនីតិវិធីទាំងមូល នៅក្នុងសំណុំរឿងដែលពាក់ព័ន្ធ និងទាក់ទងនីតិវិធីផ្សេងណាមួយនៅចំពោះមុខ តុលាការ និង នៅបន្តអនុវត្តរហូតទាល់តែវិធានការនោះ ត្រូវបានលប់ចោល ឬ ប្រែដោយយោង តាមបទប្បញ្ញត្តិនៃសេចក្តីណែនាំអនុវត្តនេះ ។

៤.២ នៅពេលដែលសហព្រះរាជអាជ្ញាតំរូវអោយបង្ហាញព័ត៌មាន ក្នុងករណីណាមួយ ដែលមានចែងនៅ ក្នុងវិធានផ្ទៃក្នុង នៅក្នុងដំណាក់កាលនីតិវិធីបន្ទាប់ សហព្រះរាជអាជ្ញាត្រូវគោរពវិធានការការពារ ដែលចេញមុនដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ហើយសហព្រះរាជអាជ្ញាត្រូវ ប្រាប់អំពីវិធានការការពារនេះដល់មេធាវីការពារក្តី អំពីបុគ្គលដែលត្រូវការពារ ដែលបានកំណត់ ដោយវិធានការការពារ ដែលបានចេញរួចហើយ។

៤.៣ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬ តាមការស្នើសុំរបស់ភាគីណាមួយ សហចៅក្រមស៊ើបអង្កេត ឬអង្គ ជំនុំជម្រះអាចធ្វើការកែប្រែវិធានការការពារបាន ។ ពាក្យសុំកែប្រែវិធានការការពារ ត្រូវដាក់ជូន ទៅសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលចាត់ការលើសំណុំរឿងនោះ។ ក្នុងករណីចាំបាច់ អង្គជំនុំជម្រះ ត្រូវធ្វើការសាកសួរភាគី និងក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំ ជម្រះដែលសមស្រប តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង អំពីរាល់ព័ត៌មានដែលពាក់ព័ន្ធ កិច្ចដំណើការនីតិវិធីនៅពេលដែលវិធានការការពារត្រូវចេញពីដំបូង ។

៤.៤ នៅក្នុងការចេញដីកាកែប្រែវិធានការការពារ នីតិវិធីនៃមាត្រា២ នៃសេចក្តីណែនាំអនុវត្តនេះត្រូវយកមកអនុវត្ត ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលទទួលបន្ទុកចាត់ការលើសំណុំរឿងនោះ ត្រូវព្យាយាមស្វែងរកការយល់ព្រមពីបុគ្គល ដែលដាក់ពាក្យស្នើសុំលប់ឬ ផ្លាស់ប្តូរ ឬ សុំបន្ថែមលើវិធានការការពារ ។

**មាត្រា ៥. អវសានប្បញ្ញត្តិ**

បទប្បញ្ញត្តិនៃសេចក្តីណែនាំអនុវត្តនេះ គឺបំពេញបន្ថែមទៅលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង និងកិច្ចព្រមព្រៀងបំពេញបន្ថែមស្តីអំពីសន្តិសុខ និងសុវត្ថិភាព ។

ចូលជាធរមានថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៧